# សិទ្ធិប្រឆាំងនឹងការឆ្លើយដាក់ពិរុទ្ធភាពលើខ្លួនឯង ៖ ការការពារខ្លួនដ៏ច្របូកច្របល់

*ដោយ តូនី ហលនេស*

*ថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៩*

*ប្រែសម្រួលដោយ ទែន សុខស្រីនិត*

អតីតកុមារពេទ្យឈ្មោះ សេក ដន និងអតីតឆ្មាំយាមគុក និងអ្នកសួរចម្លើយនៅមន្ទីរស-២១ ឈ្មោះ ឡាច មាន បានបង្ហាញខ្លួនជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះក្ដីជនជាប់ចោទ កាំង ហ្គេចអ៊ាវ ហៅ ឌុច ។

## សេក ដន ៖ តួលេខនិយាយពីការពិត

សេក ដន អាយុ ៤៨ឆ្នាំ មានមុខរបរជាកសិករ បានចាប់ផ្ដើមធ្វើសក្ខីកម្មដោយភាពស្រពិចស្រពិល ខណៈពេលដែលគាត់បានព្យាយាមយល់ពីសិទ្ធិប្រឆាំងនឹងការឆ្លើយដាក់ពិរុទ្ធភាពលើខ្លួនឯង និងពីករណីកិច្ចនិយាយការពិតនៅចំពោះមុខអង្គជំនុំជម្រះ ។ ក្រោយពីការអានសិទ្ធិ និងករណីកិច្ចរបស់សាក្សីបានបញ្ចប់ទៅ សេក ដន នៅតែមិនយល់ ។ ទោះបីជាសាក្សីមិនយល់ពីសិទ្ធិ និងករណីកិច្ចរបស់ខ្លួនក៏ដោយ ក៏អង្គជំនុំជម្រះបានបង្ខំឲ្យសាក្សីធ្វើសក្ខីកម្មបន្តទៀត ។ ជាលទ្ធផល ការមិនយល់ពីសារសំខាន់នៃបញ្ហាសិទ្ធិ និងករណីកិច្ចនេះបានកើតឡើងជាបន្តបន្ទាប់ក្នុងអំឡុងពេលធ្វើសក្ខីកម្ម ។

សេក ដន បានរៀបរាប់ថា កាលពីឆ្នាំ១៩៧៨នៅពេលដែលគាត់មានអាយុ១១ឆ្នាំ គាត់ត្រូវបាននាំមកកាន់មន្ទីរស-២១ដើម្បីឲ្យធ្វើការជាកុមារពេទ្យផ្ដល់ថ្នាំព្យាបាលឲ្យអ្នកទោស និងបុគ្គលិកនៅមន្ទីរស-២១ ។ នៅពេលដែលកងទ័ពវៀតណាមបានចូលមកដល់ទីក្រុងភ្នំពេញ សេក ដន បានព្យាយាមរត់គៀសខ្លួនទៅជាមួយនឹងកុមារពេទ្យដទៃទៀត ។ បើទោះបីជាគាត់មិនបានស្គាល់ ឌុច ច្បាស់ក៏ដោយ ក៏ សេក ដន បានជួបជនជាប់ចោទ ឌុច នេះម្ដងម្កាលដែរ ។ ខណៈពេលដែលត្រូវបានសួរពីអ្នកគ្រប់គ្រងដទៃទៀតនៅមន្ទីរស-២១ សេក ដន បានឆ្លើយថាគាត់មិនស្គាល់អ្នកគ្រប់គ្រងផ្សេងទៀតទេ ។

ដោយសារតែ សេក ដន មានបទពិសោធន៍ជាពេទ្យនៅមន្ទីរស-២១ ចៅក្រមបានឆ្លៀតឱកាសស៊ើបសួរពីស្ថានភាពសុខភាពរបស់អ្នកទោសមន្ទីរស-២១ ។ សេក ដន បានរៀបរាប់ថា អ្នកទោសភាគច្រើនទទួលរងនូវការដកក្រចក ដាច់ត្រចៀក ពងបែកនៅលើខ្នង ជើង និងដៃ ។ បើទោះបីជាមានការព្យាបាទជាច្រើនបែបត្រូវបានអនុវត្តក៏ដោយ ក៏ជាទូទៅថ្នាំគ្រាប់អាចម៍ទន្សាយត្រូវបានប្រើប្រាស់សម្រាប់ព្យាបាទជម្ងឺសព្វបែបយ៉ាង ។ ប៉ុន្តែប្រសិទ្ធិភាពនៃថ្នាំគ្រាប់អាចម៍ទន្សាយនេះមិនមានភាពច្បាស់លាស់នោះទេ ។ សេក ដន បាននិយាយបន្តថាអ្នកទោសទទួលបានការព្យាបាទដើម្បីការសួរចម្លើយជាបន្តទៀតតែប៉ុណ្ណោះ ។

សេក ដន មិនបានប្រទះឃើញការធ្វើទារុណកម្មដោយផ្ទាល់ភ្នែកនោះទេ ប៉ុន្តែគាត់បានឆ្លើយថា ការរងរបួសរបស់អ្នកទោសក្រោយពីការសួរចម្លើយ ច្បាស់ជាទាក់ទងនឹងសម្លេងស្រែកដែលគាត់បានឮចេញពីអគារឃុំឃាំង ។ ម្យ៉ាងវិញទៀត បើទោះបីជាគាត់មិនបានដឹងពីការពិសោធន៍ផ្នែកវិជ្ជសាស្រ្តក៏ដោយ ក៏គាត់បានសន្និដ្ឋានថានៅពេលនោះគាត់នៅក្មេងពេក ដូច្នេះគាត់មិនដឹងថាតើមានការពិសោធន៍មែននោះទេ ។

យោងតាមសម្តីរបស់ សេក ដន គ្រូពេទ្យមិនត្រូវបានការពារចំពោះភាពភ័យខ្លាចដែលបានកើតមានឡើងនៅមន្ទីរស-២១ទេ ។ ចំពោះគ្រូពេទ្យដែលធ្វើខុសត្រូវបានចោទប្រកាន់ថាជាខ្មាំង ហើយត្រូវបានចាប់ខ្លួន ។ គាត់បាននិយាយថា ឌុច គឺជាអ្នកដែលបញ្ជាឲ្យមានការចាប់ខ្លួន ។ យ៉ាងហោចណាស់ មានគ្រូពេទ្យម្នាក់បានចងកសម្លាប់ខ្លួនឯងនៅមន្ទីរស-២១ ។

ឆ្លើយតបនឹងសក្ខីកម្មរបស់ សេក ដន, ឌុច បានបង្ហាញពីសមត្ថភាពផ្នែកគណិតវិទ្យារបស់គាត់ និងបានឆ្ងុះបញ្ចាំងពីភាពខុសគ្នានៃសក្ខីកម្មរបស់ សេក ដន ។ ឌុច បាននិយាយថា ប្រសិនបើ សេក ដន នាពេលបច្ចុប្បន្នមានអាយុ៤៨ឆ្នាំ នោះមានន័យថា គាត់កើតនៅក្នុងឆ្នាំ១៩៦១ ដូច្នេះគាត់ច្បាស់ជាមានអាយុ១៧ឆ្នាំនៅពេលដែលគាត់បានមកដល់មន្ទីរស-២១នៅឆ្នាំ១៩៧៨ មិនមែនអាយុ១១ឆ្នាំដូចដែលគាត់បានអះអាងនោះទេ ។ លើសពីនេះ ឌុច បានលើកឡើងពីការយល់ច្រឡំដែលកើតមាននៅក្នុងសក្ខីកម្មរបស់ សេក ដន ។

ឆ្លើយតបនឹងភាពខុសគ្នានៃអាយុរបស់ សេក ដន មេធាវី ហ្វ្រង់ស៊័រ រូ បានកត់សម្គាល់ថា "តួលេខនេះបាននិយាយប្រាប់ឲ្យដឹងបាត់ទៅហើយ!" យ៉ាងណាមិញ ទាំងចៅក្រម និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមិនបានសួរបញ្ជាក់ថា តើ សេក ដន អាចនឹងមិនចេះរាប់លេខក្នុងអំឡុងពេលដែលគាត់នៅមន្ទីរ ស-២១នោះទេ។ ការសួរសំណួរបែបនេះអាចក្លាយជាការគូសបញ្ជាក់ដ៏មានសារសំខាន់ ដើម្បីឆ្លុះបង្ហាញពីអនក្ខរភាពរបស់សាក្សី សេក ដន ក្នុងអំឡុងពេលដែលគាត់នៅមន្ទីរស-២១ ។

## សិទ្ធិប្រឆាំងនឹងការឆ្លើយដាក់ពិរុទ្ធភាពលើខ្លួនឯងរបស់សាក្សី សេក ដន

មេធាវីការពារក្តី ហ្វ្រង់ស៊័រ រូ បានវាយប្រហារខបសគ្គមួយ នៅពេលដែលសាក្សី សេក ដន មិនព្រមឆ្លើយនឹងសំណួរខ្លះរបស់លោក។ ហ្វ្រង់ស៊័រ រូ បានទទូចនិយាយថា បើទោះបីជា សេក ដន បដិសេធមិនឆ្លើយនឹងសំណួរដាក់ពិរុទ្ធភាពលើខ្លួនឯងក៏ដោយ ក៏គាត់មិនគួរបដិសេធមិនឆ្លើយនឹងសំណួរធម្មតាដែរ ។

លោកប្រធានចៅក្រមគាំទ្រមេធាវី ហ្វ្រង់ស៊័រ រូ ចំពោះបញ្ហានេះ និងបានក្រើនរំឭកសាក្សី សេក ដន ថាបើទោះបីជាគាត់អាច"បដិសេធមិនធ្វើការឆ្លើយតបនឹងសំណួរដែលគាត់ជឿថា អាចដាក់ពិរុទ្ធភាពលើរូបគាត់ក៏ដោយ ក៏គាត់នៅតែមានកាតព្វកិច្ចនិយាយការពិត។ ប៉ុន្តែ ខណៈពេលដែលលោកប្រធានចៅក្រម និងមេធាវីការពារក្តី ហ្វ្រង់ស៊័រ រូ ជម្រុញឲ្យ សេក ដន ឆ្លើយសំណួរ យើងសង្កេតឃើញថា បញ្ហានេះមិនទាន់មានភាពច្បាស់លាស់នៅឡើយទេថា តើសិទ្ធិប្រឆាំងនឹងការដាក់ពិរុទ្ធភាពលើខ្លួនឯងរបស់ សេក ដន ត្រូវអនុវត្តសម្រាប់សំណួរដែលចៅក្រមគិតថាជាសំណួរដាក់ពិរុទ្ធភាព ឬអនុវត្តដើម្បីសួរសំណួរថា តើ សេក ដន មានគិតថាខ្លួនគាត់មានពិរុទ្ធភាពមែនដែរឬទេ។ ជាច្រើនលើក មេធាវីរបស់សាក្សីបានពន្យល់ប្រាប់ថា សាក្សី សេក ដន មានការចងចាំខ្សោយណាស់ ហើយគាត់អាចនឹងបដិសេធមិនឆ្លើយនឹងសំណួរដែលស្មុគស្មាញ ។

## ឡាច មាន ៖ អ្នកសួរចម្លើយ មិនមែនអ្នកធ្វើទារុណកម្មទេ

បន្ទាប់ពីការឈប់សម្រាកអាហារថ្ងៃត្រង់ អង្គជំនុំជម្រះបានបន្តដំណើរការនីតិវិធីដោយការធ្វើសក្ខីកម្មរបស់សាក្សី ឡាច មាន។ ឡាច មាន មានអាយុ៥២ឆ្នាំ និងមានមុខរបរជាកសិករ។ គាត់បានធ្វើការនៅគុកព្រៃស ហើយបន្ទាប់មកក៏ធ្វើជាឆ្មាំយាមគុក និងអ្នកសួរចម្លើយនៅមន្ទីរស-២១ ។ ឡាច

មាន បានរៀបរាប់ថាគាត់បានឃើញឡានដឹកអ្នកទោសជនជាតិវៀតណាមមកកាន់មន្ទីរស-២១ ហើយចំណែកឯបុគ្គលិកមន្ទីរស-២១ដែលក្លាយជាអ្នកទោសវិញត្រូវបានចាប់ខ្លួនដោយមានគ្របក្រណាត់ ។ តាំងពីដើមរហូតដល់ចុងបញ្ចប់នៃថ្ងៃដែលគាត់បានធ្វើការនៅមន្ទីរស-២១ ឡាច មាន ត្រូវបានបង្រៀនពីវិធីសាស្ត្រសួរចម្លើយ ។ គាត់រៀនតាមរយៈការសង្កេតមើលអ្នកសួរចម្លើយដទៃទៀត ហើយគាត់បានបដិសេធថាមិនមានឯកសារដែលត្រូវបានយកមកប្រើប្រាស់ដើម្បីណែនាំអ្នកសួរចម្លើយទេ ។ ជាទូទៅ អ្នកសួរចម្លើយត្រូវបានបែងចែកជាក្រុមដោយយោងទៅតាមឋានៈរបស់អ្នកទោសដូចជា ៈ អ្នកទោសសំខាន់ ជនជាតិបរទេស អ្នកទោសកម្មាភិបាលស្រី និងអ្នកទោសមកពីប្រទេសលោកខាងលិច ។ ឡាច មាន បានរៀបរាប់ថាអ្នកសួរចម្លើយធម្មតាមិនត្រូវបានអនុញ្ញាតឲ្យធ្វើទារុណកម្ម និងប្រព្រឹត្តអំពើហិង្សាលើរូបរាងកាយរបស់អ្នកទោសទេ ហើយគាត់ក៏មិនដែលបានឃើញការធ្វើទារុណកម្ម បានកើតឡើងនៅមន្ទីរស-២១ដែរ ។

ជាមួយគ្នានេះ ឡាច មាន បានអះអាងថា ឌុច មិនដែលបញ្ជាឲ្យគាត់ធ្វើទារុណកម្មទេ ប៉ុន្តែ ឌុច បានទាក់ទងជាមួយគាត់ផ្ទាល់តាមរយៈគេអូដើម្បីរាយការណ៍ពីការសួរចម្លើយដែល«មិនពេញលេញ» ។ ជាចុងបញ្ចប់ ឡាច មាន បាននិយាយថា ចរន្តអគ្គិសនីត្រូវបានប្រើប្រាស់សម្រាប់ឆក់អ្នកទោស ។

ក្នុងចំណោមបញ្ហាជាច្រើន ឌុច បានបង្ហាញពីមន្ទិលសង្ស័យចំពោះការងាររបស់ ឡាច មាន ក្នុងនាមជាអ្នកសួរចម្លើយរបស់មន្ទីរស-២១ថាគាត់នឹងមិនជ្រើសរើសអ្នកសួរចម្លើយដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់ដោយផ្ទាល់នោះទេ ។

សក្ខីកម្មរបស់សាក្សី ឡាច មាន នឹងបន្តនៅថ្ងៃអង្គារ៍ ទី៤ ខែកក្កដា ។